# សិក្ខាសាលាស្តីពីយុវជន ការអប់រំ និងការងារប្រចាំឆ្នាំ២០១៦

*- ការរៀបចំជីវិតបន្ទាប់ពីបញ្ចប់ការប្រលងសញ្ញាបត្រទុតិយភូមិ -*

## ១. គោលបំណង

នៅក្នុងប្រទេសកម្ពុជា មនុស្សជាច្រើនបានយល់ឃើញថា បើចំណេះដឹងរបស់ពួកគេកាន់តែខ្ពស់ ប្រាក់ខែដែលពួកគេរំពឹងទុកក៏កាន់តែច្រើនដែរ។ ប៉ុន្តែយោងតាមការស្រាវជ្រាវជាច្រើនបានបង្ហាញឲ្យឃើញថា ការយល់ឃើញនេះមិនឆ្លុះបញ្ចាំងពីតថភាពនៅក្នុងទីផ្សារការងារឡើយ។ នេះបានសបញ្ជាក់យ៉ាងច្បាស់ថាទីផ្សារការងារនាពេលបច្ចុប្បន្ន គឺទាមទារនូវអ្នកមានជំនាញទាក់ទងនឹងបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានការកើនឡើងជាលំដាប់ទាំងក្នុងក្រុមហ៊ុនកម្ពុជា និងជប៉ុន តែមិនមែនការសិក្សាថ្នាក់ខ្ពស់នោះទេ។ ស្របពេលជាមួយគ្នានេះដែរ ប្រទេសកម្ពុជាកំពុងតែចូលខ្លួនបន្តិចម្តងៗទៅក្នុងបរិបទសេដ្ឋកិច្ចអន្តរជាតិ។ ដូច្នេះហើយតម្រូវការបុគ្គលិកផ្នែកពាណិជ្ជកម្មអន្តរជាតិនិង សន្និធិ(logistic) កំពុងតែទទួលបានការយកចិត្តទុកដាក់ជាខ្លាំងដែរ។

ដើម្បីកាត់បន្ថយនូវការមិនស៊ីសង្វាក់គ្នារវាងការអប់រំ និងតំរូវការការងារ យើងខ្ញុំបានរៀបចំកម្មវិធីនេះ ដើម្បីធ្វើឲ្យយុវជន ក៏ដូចជាសិស្សនិស្សិត ងាកមកចាប់អារម្មណ៍លើជំនាញបច្ចេកទេស និង ផ្នែកពាណិជ្ជកម្មអន្តរជាតិ និងសន្និធិ(logistic) ថែមទៀត។ ជាពិសេសសិស្សានុសិស្សដែលទើបតែប្រលងបញ្ចប់ការសិក្សាពីវិទ្យាល័យឆ្នាំនេះ គឺគួរតែសំលឹងមើល និងយល់អំពីសារៈសំខាន់នៃការសិក្សាមុខវិជ្ជាដែលជាតម្រូវការយ៉ាងខ្ពស់នៅក្នុងវិស័យរដ្ឋ និងឯកជន។ ប្រសិនបើយើងអាចធ្វើដូច្នេះបាន យើងប្រាកដជានឹងអាចកាត់បន្ថយភាពមិនស៊ីគ្នានៅក្នុងទីផ្សារការងារប្រទេសកម្ពុជា ដោយក្រុមហ៊ុននឹងមានអ្នកជំនាញជាច្រើនសំរាប់ពួកគេ ដោយមិនចាំបាច់មានការជួលពីក្រុមហ៊ុនបរទេស និងនិស្សិតដែលបញ្ចប់ពីសាលាជំនាញនានានឹងអាចមានការងារធ្វើ។ ពួកយើងនឹងអាចកាត់បន្ថយបាន នូវអត្រាចំនួនយុវជនដែលអត់ការងារធ្វើ ព្រមទាំងអាចបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ពង្រឹងមូលដ្ឋានគ្រឹះឧស្សាហកម្ម និងសេដ្ឋកិច្ចដ៏ខ្លាំងក្លានៅថ្ងៃអនាគត។

## ២.កម្មវិធី

**ថ្ងៃទី១៖** ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ពីម៉ោង ៧:៣០ ដល់ម៉ោង ១៧:៤៥ នៅបន្ទប់អង្គរ-គីស្សូណា, CJCC

មាតិកាៈ

- ❖ បទបង្ហាញស្តីពីតួនាទីវិទ្យាសាស្ត្រនិងបច្ចេកទេស ព្រមទាំងពាណិជ្ជកម្មអន្តរជាតិនិងសន្និធិក្នុងសង្គម
- ❖ ការពិភាក្សានិងព្រឹក្សាយោបល់ពីសិស្សច្បងដែលបានជ្រើសរើសនូវជំនាញនៃការសិក្សា ហើយពួកគេព្យាយាមសម្រេចគោលដៅជីវភាពផ្អែកទៅលើចំណង់ចំណូលចិត្ត ទេពកោសល្យ គម្រោងជីវិត និងតម្រូវការទីផ្សារការងារ
- ❖ ការធ្វើតេស្តសមត្ថភាពពីកំណើត ដើម្បីជួយពួកគេឲ្យដឹងពីទេពកោសល្យពីកំណើត សក្តានុពលសមត្ថភាពដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការជ្រើសរើសជំនាញសិក្សាដោយមានប្រសិទ្ធិភាព
- ❖ បទបង្ហាញស្តីពី ការបែងចែករវាងតម្រូវការការងារ និងការផ្គត់ផ្គង់ក្នុងទីផ្សារនៃប្រទេសកម្ពុជាៈ តម្រូវការជំនាញដោយក្រុមហ៊ុនជាច្រើនក្នុង១០វិស័យ
- ❖ ការពិភាក្សាទៅលើប្រភេទធនធានមនុស្ស និងជំនាញដែលក្រុមហ៊ុនត្រូវការជាក់ស្តែង

**ថ្ងៃទី២ៈ** ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ពីម៉ោង ៧:៣០ ដល់ម៉ោង ១៧:៣០

(ទស្សនកិច្ចសិក្សានៅតាមសាលា និងក្រុមហ៊ុន)

មាតិកាៈ

- ❖ ស្វែងយល់ពីបរិយាកាសកន្លែងសិក្សា ដូចជាការចូលមើលមន្ទីរពិសោធន៏ និងសាកសួរសំនួរទាក់ទងនិងការសិក្សារពីសាស្ត្រាចារ្យ និងនិសិត្សដែលកំពុងសិក្សានៅសាលានោះ
- ❖ ស្វែងយល់ពីបរិយាកាសការងារ ដូចជាតួនាទីអ្វីត្រូវនឹងប្រភេទការងារបែបណា និងតម្រូវការជាក់ស្តែងពីក្រុមហ៊ុន

**ថ្ងៃទី៣ៈ** ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ពីម៉ោង ៧:៣០ព្រឹក ដល់ម៉ោង ១៧:០០ល្ងាច នៅសាលប្រជុំ NEA

មាតិកាៈ

- ❖ ការបណ្តុះបណ្តាលអំពីផែនការជីវិត និងផែនការអាជីព
- ❖ ការព្រឹក្សាយោបល់អំពីមុខវិជ្ជាដែលត្រូវសិក្សា

## ៣. សហការរៀបចំដោយ

- ❖ ក្រុមនិស្សិតស្ម័គ្រចិត្ត The Next-Step: Education

- ក្រុមនិស្សិតស្ម័គ្រចិត្តនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- សមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន (JAC)
- មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA)

## ៤. សហការឧបត្ថម្ភកម្មវិធីដោយ

- Coca-cola (TBC)
- DKSH (TBC)

## ៥. គាំទ្រកម្មវិធីដោយ

- Confirel
- CDRI
- Health Time Magazine
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC)
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA, TBC)
- ក្រុមអតីតសិស្សវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង

## ៦. លទ្ធផលរំពឹងទុក

- សិស្សានុសិស្សនឹងមានទំនុកចិត្តបន្ថែមក្នុងការជ្រើសរើសមុខជំនាញអាស្រ័យទៅលើគម្រោងជីវិតនិងគម្រោងអាជីពរបស់ពួកគេ
- ក្រៅពីនេះពួកគេអាចយល់ដឹងពីតម្លៃអត្ថន័យនៃជំនាញផ្សេងៗ និងតម្រូវការការងារក្នុងទីផ្សារការងារ
- ភាគច្រើននៃពួកគេនឹងជ្រើសរើសសិក្សាជំនាញខាងស្ថាបត្យកម្ម សំណង់ បច្ចេកទេស ពាណិជ្ជកម្ម អន្តរជាតិ និងសន្និធិ ជាដើម

## ៧. របៀបវីរៈ (រក្សាសិទ្ធក្នុងការកែប្រែ)

**ថ្ងៃទី១៖** ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ពីម៉ោង ៧:៣០ ដល់ម៉ោង ១៧:៤៥ នៅសាលអង្គរ-គីស្សូណា CJCC

| **ម៉ោង** | **សកម្មភាព** | **អ្នកទទួលបន្ទុក** |
|---|---|---|
| ៧:២០ – ៧:៣០ | ការជួបជុំគ្នាមុនពេលកម្មវិធីចាប់ផ្ដើម ត្រៀមខ្លួនប្រារព្ធកម្មវិធី | ក្រុមការងារ |
| ៧:៣០ – ៨:00 | ការចុះឈ្មោះ | ផ្នែកណែនាំផ្លូវ, ផ្នែកចុះឈ្មោះ |
| ៨:00 | គោរពភ្លេងជាតិ | ពិធីករ |
| ៨:00 – ៨:0៥ | បើកកម្មវិធី, បុព្វកថាភ្ញៀវកិត្តិយស | ពិធីករ |
| ៨:0៥– ៨:២០ | ការឡើងប្រកាសបើកកម្មវិធី និងមតិសំណេះសំណាល | TBC |
| ៨:២០ – ៨:៥០ | ការសំដែងរឿងខ្លី (សេចក្ដីណែនាំទាក់ទងនឹងកម្មវិធី) | ក្រុមអ្នកសំដែង |
| ៨:៥០ – ៩:៣៥ | **បទបង្ហាញគោលទី១** | លោកបណ្ឌិត Chhem Rethy, នាយកនៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) ស្ដីអំពី «តើវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជួយសង្គមបែបណា?» (How do science and technology help the society?) |
| ៩:៣៥ – ៩:៥០ | សម្រាកអាហារសម្រន់ | |
| ៩:៥០ -១០:២០ | **បទបង្ហាញគោលទី២** | លោក ទិត្យ សីលា សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ស្ដីអំពី«ពាណិជ្ជកម្មអន្តរជាតិ និងការគ្រប់គ្រង់សន្និធិនៃសា«សារសំខាន់នៃពាណិជ្ជកម្មអន្តរជាតិ និងការគ្រប់គ្រង់សន្និធិ» |
| ១០:២០ – ១២:00 | **វេទិការពិភាក្សានិងព្រឹក្សាយោបល់ពី សិស្សច្បង** | ភ្ញៀវកិត្តយស (TBC):<br>• Mr. Khuth Rathpisey, CEO of Silka Distributor in Cambodia |

| | | |
|---|---|---|
| | • វិធីសាស្ត្រក្នុងការជ្រើសរើសមុខជំនាញឲ្យបានត្រឹមត្រូវតាម បទពិសោធន៍ផ្ទាល់ខ្លួន<br>• មូលហេតុដែលជ្រើសរើសមុខជំនាញបច្ចុប្បន្ន<br>• ជំរុញនិងលើកទឹកចិត្តសិស្សប្អូន<br>អ្នកសម្របសម្រួលដោយៈ លោក នុត សីហា នៃ DKSH | • លោក សាំង តារាស្មី ចាងហ្វាងការផ្សាយទស្សនាវដ្តី ហោលស៍ថាម<br>• លោក ធិន ឌីម៉ង់ ជាបុគ្គលិកផ្នែកទំនាក់ទំនងសាធារណៈ នៃមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន<br>• Mr. Ieng Vichhai, General Director, IDOUDO |
| ១២:00 – ១៣:00 | សម្រាកបាយថ្ងៃត្រង់ | |
| ១៣:00 – ១៥:00 | កម្រងសំណួរស្វែងយល់ពីការរៀបចំផែនការអាជីពនិងការសិក្សា | ក្រុមការងារ NEA |
| ១៥:00 – ១៥:១៥ | សម្រាកអាហារសម្រន់ | |
| ១៥:១៥ – ១៥:៤៥ | បទបង្ហាញស្តីអំពីតម្រូវការព័ត៌មានទីផ្សារការងារនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ | តំណាង NEA (TBC) |
| ១៥:៤៥ – ១៧:00 | វេទិការពិភាក្សានិងព្រឹក្សាយោបល់ពីនិយោជិកស្តីអំពី **«ប្រភេទបុគ្គលិកដែលក្រុមហ៊ុនត្រូវការ»** | ភ្ញៀវកិត្តយស<br>• Dr Hay Ly Eang, founder of Confirel |
| ១៧:00 – ១៧:១៥ | ការចាប់ឆ្នោត និង បិទកម្មវិធីថ្ងៃទី១ | ក្រុមការងារ និងពិធីករ |
| ១៧:១៥ – ១៧:៣0 | កិច្ចប្រជុំសម្រាប់ទស្សនកិច្ចថ្ងៃបន្ទាប់ | អ្នកចូលរួមកម្មវិធី |
| ១៧:៣0 – ១៧:៤៥ | កិច្ចប្រជុំសម្រាប់ទស្សនកិច្ចថ្ងៃបន្ទាប់ | ក្រុមការងារ |
| ១៧:៤៥ | ចប់កម្មវិធីថ្ងៃទី១ | |

**ថ្ងៃទី២៖** ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០១៦ (ទស្សនកិច្ចសិក្សាទៅសាលា និង ក្រុមហ៊ុន)

| ម៉ោង | សកម្មភាព | គោលបំណង |
|---|---|---|
| ៧:៣០ – ៧:៤០ | ជួបជុំគ្នានៅ CJCC | ស្វែងយល់ពីបរិយាកាសកន្លែងសិក្សាដូចជា ការចូលមើលមន្ទីរពិសោធន៍ និង សាកសួរសំនួរ ទាក់ទងនឹងការសិក្សាទៅកាន់ សាស្ត្រាចារ្យ និង និសិត្សដែលកំពុងសិក្សា |
| ៧:៤០ | ចេញដំណើរទៅសាលា | |
| ៧:៤០– ៨:០០ | មកដល់សាលាទី១ | |
| ៨:០០ – ៩:៣០ | ក្រុមA: វិទ្យាស្ថានបច្ចេកវិទ្យានៃកម្ពុជា ( TBC)<br>ក្រុមB: សាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូង (TBC) | |
| ៩:៣០ – ១០:០០ | ចេញដំណើរទៅសាលាទី២ | |
| ១០:០០ – ១១:៣០ | ក្រុមA: សាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូង (TBC)<br>ក្រុមB: វិទ្យាស្ថានបច្ចេកវិទ្យានៃកម្ពុជា (TBC) | |
| ១១:៣០ – ១២:០០ | ចេញដំណើរទៅ CJCC | |
| ១២:០០ | មកដល់ CJCC វិញ | |
| ១២:០០ – ១៣:០០ | សម្រាកបាយថ្ងៃត្រង់ ( CJCC) | |
| ១៣:០០ – ១៣:៣០ | ធ្វើដំណើរទៅកាន់ក្រុមហ៊ុន ១ | ស្វែងយល់ពីបរិកាសការងារ ដូចជាតួនាទីអ្វីត្រូវនឹងប្រភេទការងារបែបណា និងតម្រូវការជាក់ស្តែងពីក្រុមហ៊ុន |
| ១៣:៣០ – ១៥:០០ | ក្រុមA: ក្រុមហ៊ុនកសិឧស្សាហកម្ម Confirel (TBC)<br>ក្រុមB: Minebea (Cambodia) Co., Ltd. (TBC) | |
| ១៥:០០ – ១៥:៣០ | ធ្វើដំណើរទៅដល់ក្រុមហ៊ុន២ | |
| ១៥:៣០ – ១៧:០០ | ក្រុមA: Minebea (Cambodia) Co., Ltd. (TBC)<br>ក្រុមB: ក្រុមហ៊ុនកសិឧស្សាហកម្ម Confirel (TBC) | |
| ១៧:០០ – ១៧:៣០ | ចេញដំណើរទៅ CJCC | |
| ១៧:៣០ | បញ្ចប់ទស្សនកិច្ចសិក្សាថ្ងៃទី២ | |

**ថ្ងៃទី៣៖** ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០១៦

| ម៉ោង | សកម្មភាព | គោលបំណង |
|---|---|---|
| ៧:៣០ | ជួបជុំគ្នា NEA | • ជួយឲ្យសិស្សទាំងឡាយរៀនចេះគិតពីផ្លូវជីវិតរបស់ខ្លួន ចេះធ្វើផែនការជីវិតដោយខ្លួនឯងផ្ទាល់<br>• ជួយឲ្យសិស្សមានចំណេះដឹងអំពីមុខវិជ្ជាទាំងឡាយមុនពេលពួកគេសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សា |
| ៧:៣០ – ១១:៣០ | ក្រុម A: វគ្គបណ្ដុះបណ្ដាលអំពីការរៀបចំផែនការជីវិត (Life Path Training)<br>ក្រុម B: ការព្រឹក្សាយោបល់ជាមួយសិស្ស អំពី **«មុខវិជ្ជាសិក្សា»** | |
| ១១:៣០ – ១៣:00 | សម្រាកថ្ងៃត្រង់ | |
| ១៣:00 -១៧:00 | ក្រុមB: វគ្គបណ្ដុះបណ្ដាលអំពីការរៀបចំផែនការជីវិត (Life Path Training)<br>ក្រុមA: ការព្រឹក្សាយោបល់ជាមួយសិស្ស អំពី **«មុខវិជ្ជាសិក្សា»** | |
| ១៧:00 | ចប់សិក្ខាសាលា | |

*(យើងខ្ញុំសូមរក្សាសិទ្ធក្នុងការកែប្រែ)*